ធ៩-៩៨-៤១១ ប្រក

# ប្រកាស

# ស្តីពី

# ការផ្ទេរប្រាក់របស់ធនាគារពាណិជ្ជ

# តាមរយៈធនាគារជាតិនៃកម្ពុជា

**ប្រការ ១** : បញ្ឈប់ការផ្តល់ទិដ្ឋាការអោយធនាគារពាណិជ្ជនាំចេញនូវសាច់ប្រាក់ជាដុល្លារអាមេរិកតទៅទៀត ដោយអនុញ្ញាត អោយធ្វើការផ្ទេរប្រាក់តាមរយៈធនាគារជាតិនៃកម្ពុជា ។

**ប្រការ ២** : ធនាគារពាណិជ្ជដែលមានបំណងផ្ទេរសាច់ប្រាក់ដុល្លារចេញ ត្រូវសុំការអនុញ្ញាតជាមុនពីធនាគារជាតិនៃកម្ពុជា (នាយកដ្ឋានគ្រប់គ្រងការប្តូរប្រាក់) ។

**ប្រការ ៣** : សោហ៊ុយសេវាក្នុងប្រតិបត្តិការផ្ទេរប្រាក់នឹងត្រូវកំណត់ទៅតាមកាលៈទេសៈតំរូវការសាច់ប្រាក់ ដុល្លារ អាស្រ័យដោយអគ្គនាយកដ្ឋានធនាគារជាតិនៃកម្ពុជា ជាអ្នកសំរេចចេញសេចក្តីជូនដំណឹងអោយ អនុវត្តជាក់ស្តែងប្រចាំគ្រា នីមួយៗ ។

**ប្រការ ៤** : រាល់ប្រកាស ឬ លិខិតបទដ្ឋានទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីស្មារតីនៃប្រកាសនេះ ជាពិសេស ប្រកាសលេខ ធ៧៩៨-៣៦៦ ប្រក ចុះថ្ងៃទី១៥ ខែមិថុនា ១៩៩៨ និងប្រកាស លេខធ៩៩៨-៣៨៦ ប្រក ចុះថ្ងៃទី២៣ ខែ កក្កដា ១៩៩៨ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ ៥** : អគ្គលេខាធិការដ្ឋាន អគ្គនាយកដ្ឋាន អគ្គបេឡា អគ្គាធិការដ្ឋាន គ្រប់នាយកដ្ឋាន-អង្គភាព គ្រប់គ្រឹះស្ថានធនាគារ និងគ្រឹះស្ថានហិរញ្ញវត្ថុ នៅក្រោមឱវាទ និងក្រោមអាណាព្យាបាលធនាគារជាតិ នៃកម្ពុជា មានភារកិច្ចរៀងៗខ្លួន អនុវត្តតាមប្រកាសនេះ ។

**ប្រការ ៦** : ប្រកាសនេះមានប្រសិទ្ធិភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី០១ ខែតុលា ឆ្នាំ១៩៩៨

**ទេសាភិបាល**

ហត្ថលេខា និងត្រា **ជា ចាន់តូ**